# ការជជែកជាមួយអេឡៃន អំពីមាត្រានៃសេចក្ដីជំនឿ

*អេឡៃន មកពី ម៉ាឡាហ្គា ប្រទេសអេស្ប៉ាញ ។ យើងបានសួរគាត់នូវសំណួរមួយចំនួនអំពីរបៀបដែលគាត់បានរៀនអំពីមាត្រានៃសេចក្ដីជំនឿ ។*





### សូមប្រាប់យើងអំពីខ្លួនរបស់ប្អូន ។

ខ្ញុំមានអាយុ ៨ ឆ្នាំ ។ នៅពេលខ្ញុំធំឡើង ខ្ញុំចង់ក្លាយជាអ្នកវិទ្យាសាស្ត្រដ៏ល្បីម្នាក់ ។ ពណ៌ដែលខ្ញុំចូលចិត្ត គឺពណ៌ទឹកក្រូច ហើយអាហារដែលខ្ញុំចូលចិត្តគឺ *tortillas de patatas* ( ស៊ុតចៀនអេស្ប៉ាញ ) ដែលលោកយាយរបស់ខ្ញុំធ្វើ ។



### តើប្អូនបានរៀនមាត្រានៃសេចក្ដីជំនឿដោយរបៀបណា ?

ខ្ញុំបានចាប់ផ្ដើមរៀនវានៅក្នុងអង្គការបឋមសិក្សា ។ យើងច្រៀងចម្រៀងដើម្បីជួយយើងចងចាំ ។ ពេលខ្លះគ្រូរបស់យើងបានសរសេរនៅលើក្ដារខៀន ហើយលុបពាក្យមួយចំនួន ។ យើងក៏បានគូររូបភាពដើម្បីពន្យល់អំពីមាត្រានៃសេចក្ដីជំនឿនីមួយៗផងដែរ ។

ខ្ញុំក៏បានអនុវត្តការសូត្រមាត្រានៃសេចក្ដីជំនឿ ជាមួយគ្រួសាររបស់ខ្ញុំនៅក្នុងឡាននៅតាមផ្លូវទៅសាលារៀនផងដែរ ។ ខ្ញុំកំពុងជួយប្អូនស្រីរបស់ខ្ញុំ ម៉ាយ៉ា រៀនផងដែរ ។ នាងចេះប្រាំមួយមាត្រាដំបូងហើយ !



### តើមាត្រានៃសេចក្ដីជំនឿមួយណាដែលប្អូនពេញចិត្តជាងគេ ?

ខ្ញុំចូលចិត្តមាត្រាទីប្រាំបួន ។ « យើងខ្ញុំជឿចំពោះការណ៍ទាំងអស់ ដែលទ្រង់បានបើកសម្ដែងមក និងការណ៍ទាំងអស់ ដែលទ្រង់បើកសម្ដែងនៅពេលឥឡូវនេះ ហើយយើងខ្ញុំជឿថាទ្រង់នឹងបើកសម្ដែងនូវការណ៍ដ៏ធំ និងសំខាន់ៗជាច្រើន ដែលទាក់ទងទៅនឹងនគរនៃព្រះ » ។ វាបង្រៀនថាព្រះវរបិតាសួគ៌មានការណ៍បន្ថែមទៀតសម្រាប់យើងដើម្បីរៀនបន្តិចម្ដងៗ ។

### តើការចេះដឹងអំពីមាត្រានៃសេចក្ដីជំនឿបានជួយប្អូនយ៉ាងដូចម្ដេច ?

មានថ្ងៃមួយនៅសាលា មិត្តរបស់ខ្ញុំ សូហ្វីយ៉ា បានសួរខ្ញុំអំពីអ្វីដែលខ្ញុំជឿ ហើយថាតើខ្ញុំជាសមាជិករបស់សាសនាណាមួយឬទេ ។ ខ្ញុំបានចាំមាត្រាទីមួយនៃមាត្រានៃសេចក្ដីជំនឿដែលនិយាយថា « យើងខ្ញុំជឿដល់ព្រះ គឺព្រះវរបិតាដ៏គង់នៅអស់កល្បជានិច្ច និងដល់ព្រះរាជបុត្រាទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ ហើយដល់ព្រះវិញ្ញាណបរិសុទ្ធ » ។ ដូច្នេះ ខ្ញុំបានចែកចាយមាត្រានោះជាមួយនឹងនាង ។

ខ្ញុំក៏បានប្រាប់នាងផងដែរថា ខ្ញុំគឺជាគ្រីស្ទានម្នាក់ និងជាសមាជិកនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។ នាងបានស្ដាប់ខ្ញុំ ហើយយល់ពីអ្វីដែលខ្ញុំបានចែកចាយជាមួយនាង ។

### តើបទពិសោធន៍របស់ប្អូនជួយឲ្យប្អូនមានអារម្មណ៍បែបណា ?

ខ្ញុំមានអារម្មណ៍ល្អណាស់ដោយសារខ្ញុំដឹងថា ខ្ញុំក្លាហានក្នុងការចែកចាយជំនឿរបស់ខ្ញុំជាមួយមិត្តភក្ដិរបស់ខ្ញុំ ។ ដោយសារតែការខិតខំរៀនសូត្ររបស់ខ្ញុំអំពីមាត្រានៃសេចក្ដីជំនឿ នោះខ្ញុំអាចចែកចាយដំណឹងល្អ ហើយដឹងពីអ្វីដែលត្រូវនិយាយ ។

